*Kampuchean Action for Primary Education*

## អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

# ឯកសារ

# ការរៀបចំផ្សារប្រឌិត

**កំពង់ចាម , ខែ កក្កដា ២០០៤**

**ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា**

# ការរៀបចំផ្សារប្រឌិត

## ( Organizing Market Simulation )

**សេចក្តីផ្តើម** :

ក្រសួងអប់រំយុវជន និង កីឡា មានគោលការណ៍ដើម្បីពង្រីកទៅលើសកម្មភាពផ្នែកបំណិនជីវិត ដើម្បីជួយជំរុញការអភិវឌ្ឍន៍របស់កុមារ ។ កម្មវិធីនេះជួយលើកស្ទួយបំណិនជីវិតរបស់កុមារ ដូចជា : ធ្វើការសំរេចចិត្តដោយបំណិនវិភាគ និង បំណិនច្នៃប្រឌិត ។ កុមារមានភាពទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍របស់គេ ព្រមទាំងមានឱកាសធ្វើការសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីសំរេចនូវគោលបំណង ។ ជាងនេះទៅទៀត កុមារពិតជាមានការអភិវឌ្ឍទៅលើជំនាញបច្ចេកទេសរបស់ពួកគេ ។

ថ្មី ៗ នេះ កម្មវិធីសាលាកុមារមេត្រី មានសកម្មភាព ២ ដែលកំពុងអភិវឌ្ឍន៍បំណិនទាំងនេះ ។ សហគមន៍ គឺជាមូលដ្ឋានរបស់កម្មវិធីបំណិនជីវិត និង សមាគមសិស្ស ។ នៅក្នុងឯកសារនេះ សកម្មភាពទី ៣ ( ដែលពុំមាននៅក្នុងកម្មវិធីសិក្សា ) ត្រូវបានណែនាំដែលអាចជួយពង្រឹងដល់បំណិនផ្នែកគណិតវិទ្យា និង ចំណេះដឹងផ្សេងៗ ទៀត ។ សកម្មភាពនេះត្រូវបានគេដាក់ឈ្មោះថា " ផ្សារប្រឌិត " ។

ផ្សារប្រឌិត បានជំរុញអោយសិស្សប្រើបំណិនតាមប្រភេទនីមួយ ៗ ព្រមទាំងបំណិនបច្ចេកទេសច្បាស់លាស់ ដើម្បីអភិវឌ្ឍន៍ដល់សហគមន៍ដែលជាមូលដ្ឋានរបស់កម្មវិធីបំណិនជីវិត ។ សិស្សត្រូវបានផ្តល់ឱកាសក្នុងការប្រើប្រាស់ថវិកានៅក្នុងផ្សារប្រឌិតដែលរៀបចំនៅតាមសាលារៀន ដែលទាក់ទងទៅនឹង ការទិញ , លក់ , ការថែរក្សាសៀវភៅ , ការខ្ចីប្រាក់ និង អាទិភាពក្នុងការទិញ ។ សកម្មភាពផ្សារប្រឌិត គឺជាមូលដ្ឋានមួយដែលមានការពឹងផ្អែកទៅលើកម្មវិធីបំណិនជីវិត ។ ជាការពិតសកម្មភាពរបស់ផ្សារប្រឌិតត្រូវបានអនុវត្តនៅពេល ឬ បន្ទាប់ពីកម្មវិធីបំណិនជីវិតត្រូវបានបញ្ចប់ ។ ទោះបីជាយ៉ាងណាក៏ដោយសកម្មភាពបំណិនជីវិត សកម្មភាពផ្សារប្រឌិត និង សមាគមសិស្ស និងចាប់ផ្តើមអនុវត្តរួមគ្នា ក៏ប៉ុន្តែចំពោះសមាគមសិស្សមិនចាំបាច់មានក៏បានដែរ តែដាច់ខាតត្រូវតែមានសម្មភាពបំណិនជីវិត នៅចុងបញ្ចប់នៃឯកសារនេះ មានការពណ៌នាខ្លីមួយដែលបានដាក់បញ្ចូលទៅក្នុងតួនាទីរបស់សមាគមសិស្ស ក្នុងផ្សារប្រឌិតសម្រាប់សាលារៀនណាដែលបានបង្កើតកម្មវិធីសមាគមសិស្សរួចហើយ ។

## 1. គោលបំណង :

1) ជួយសាលារៀន ដើម្បីគិតអំពីទស្សនរបស់ផ្សារប្រឌិត ។

2) ជួយសាលារៀន ដើម្បីកំណត់បញ្ហាដែលទាក់ទងនិងការរៀបចំផ្សារប្រឌិត ។

## 2. ការពណ៌នាអំពីផ្សារប្រឌិត :

នៅក្នុងកម្មវិធីបំណិន ចំពោះសិស្សថ្នាក់ទី ៥ និង ថ្នាក់ទី ៦ មានឱកាសដើម្បីទម្លាប់ខ្លួនរបស់គេជាមួយបំណិនផ្សេង ៗ ក្នុងរយៈពេល ១០ សប្តាហ៍ ។ ផ្សារប្រឌិត និងចាប់ផ្តើមក្នុងសប្តាហ៍ទី ១១ និង សប្តាហ៍ទី ១៤ ។ សិស្សមួយចំនួនធ្វើជាអ្នកលក់

និង មួយចំនួនទៀត ជាអ្នកទិញ ។ នេះគឺយោលទៅតាមចំនួនសិស្សដែលមាននៅក្នុងថ្នាក់ទី ៥និង ថ្នាក់ទី ៦ ។ សិស្សទាំងអស់អាចរកលុយសិប្បនិម្មិត ( លុយក្រដាស ) តាមរយៈការចូលរៀនរៀងរាល់ថ្ងៃ និង អនុវត្តសកម្មភាពជាក់ស្តែងនៅក្នុងសាលាដូចជា : សំអាតបន្ទប់រៀន , ទីធ្លាសាលារៀន , សំអាតបង្គន់ , ធ្វើការងារក្នុងសួន ឬ ជួយដល់គ្រូ ។ល ។ គេអាចសន្សំលុយបានពីការចាប់ផ្តើមកម្មវិធីបំណិនជីវិត ។ បន្ទាប់ពី ១០ សប្តាហ៍ ផ្សារប្រឌិតត្រូវបានរៀបចំ ហើយសិស្សទាំងអស់អាចផ្តល់នូវសេវាកម្មដែលគេបានរៀនក្នុងកម្មវិធីបំណិនជីវិត ឬ ក្នុងកម្មវិធីគេហកិច្ចដូចជា : ការកាត់សក់ , ការលេងឧបករណ៍ភ្លេងបុរាណ ការកាត់ដេរ , ជួសជុលកង់ និង លក់អាហារ ។ល។ គេអាចលក់ផលិតផលដែលសាលាបានទិញ ឬ គេអាចផ្តល់សេវាកម្មដែលសាលាបានគាំទ្រសេវាកម្មទាំងនោះ ដូចជា : ការលក់អាហារក្នុងភោជនីយដ្ឋាន , មើលវីដេអូ , សិល្បៈ , គំនូរ ឬ លេងល្បែងល្បងប្រាជ្ញា ( ល្បែងដោះស្រាយចម្ងល់ ការគិតដោយវិភាគ និង ការគិតដោយច្នៃប្រឌិត ) ។

## 3. ការរៀបចំសកម្មភាពផ្សារប្រឌិត :

### 3.1. ការតម្រង់ទិសដល់គ្រូ និង សហគមន៍ :

វគ្គតម្រង់ទិសសម្រាប់គ្រូ និង សហគមន៍ និងចាប់ផ្តើមធ្វើស្តីពីផ្សារប្រឌិត ( មើលឧបសម្ព័ន្ធ **A** : ការតម្រង់ទិសពីផ្សារប្រឌិតសម្រាប់គ្រូ និង សហគមន៍ ) ។

### 3.2. ការតម្រង់ទិសដល់សិស្ស :

គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ទាំងអស់ និងចាប់ផ្តើមធ្វើមេរៀនសម្រាប់បង្រៀនសិស្សរបស់គេអំពីផ្សារប្រឌិត ( មើលឧបសម្ព័ន្ធ **B** : ការតម្រង់ទិសអំពីផ្សារប្រឌិតសម្រាប់សិស្ស ) ។

### 3.3. ការអនុវត្តសកម្មភាពនៅលើផ្សារប្រឌិត :

គ្រូថ្នាក់ទី ៥ និង ទី ៦ ត្រូវរៀបចំសកម្មភាពផ្សារប្រឌិត ( មើលឧបសម្ព័ន្ធ **C** : ការអនុវត្តសកម្មភាពផ្សារប្រឌិត ) ។

### 3.4. ការវាយតម្លៃសកម្មភាពផ្សារប្រឌិត :

នៅពេលកម្មវិធីបំណិនជីវិត និង ផ្សារប្រឌិត ត្រូវបញ្ចប់សិស្សត្រូវសរសេរស្តីពីការវាយតម្លៃទៅលើសេវាកម្មដែលពួកគេបានផ្តល់ជូនសាលា ( ( មើលឧបសម្ព័ន្ធ **D** : ការវាយតម្លៃលើសកម្មភាពផ្សារប្រឌិត ) ។

ចំពោះសកម្មភាពដែលរៀបរាប់ខាងលើ ត្រូវបានធ្វើការបំប៉នដោយបុគ្គលិក ខេប មុនពេលយកទៅតម្រង់ទិសសម្រាប់គ្រូនៅតាមសាលា ។

## 4. ថវិកាសម្រាប់សកម្មភាពផ្សារប្រឌិត :

សាលារៀនដែលមានកម្មវិធី " សកម្មភាពផ្សារប្រឌិត " ដែលនឹងត្រូវចាប់ផ្តើម បានទិញសម្ភារមួយចំនួនសម្រាប់សហគមន៍ក្នុងការបំប៉នផ្នែកបំណិនជីវិតរួចហើយ ។ ហេតុដូច្នេះ ចំណុចខាងក្រោមនេះមិនចាំបាច់ទិញសម្ភារបន្ថែមទៀតទេ ។

1) ការកាត់សក់ : ការជួល ឬ ទិញសម្ភារ
2) ការជួសជុលកង់ : ការជួល ឬ ទិញឧបករណ៍ជួសជុល

3) ការប្រគុំភ្លេងបុរាណ : ការជួលឧបករណ៍ភ្លេង

4) ការកាត់ដេរ : ការជួសជុល និង លក់សំលៀកបំពាក់ , ជួលម៉ាស៊ីនដេរ ។

ចំពោះសកម្មភាព និង សម្ភារ ខាងក្រោម ត្រូវតែគ្រោងថវិកាសម្រាប់រៀបចំ ។

1. ភោជនីយដ្ឋាន , ការជួលឆ្នាំង និង ឧបករណ៍ចំអិនអាហារផ្សេងទៀត

- ការជួលចាន និង កាំបិតផ្សេង ៗ
- អុសសម្រាប់ចំអិន
- ម្ហូប

2. ការទស្សនាវីដេអូ , ការជួលវីដេអូ

- ការជួល ឬ ទិញកាសែតវីដេអូ

3. សកម្មភាពគំនូរ សម្ភារសម្រាប់លាបពណ៌ , ក្រដាស

4. ល្បែងល្បងប្រាជ្ញាថតចម្លង ល្បែងការគិតដោយវិភាគ និង ច្នៃប្រឌិត

5. ថតចម្លងលុយក្រដាស

6. អាហារ និង ភេសជ្ជៈសម្រាប់សិក្ខាសាលា

7. សម្ភារសម្រាប់តម្រង់ទិស

ចំពោះសកម្មភាពខាងលើ គ្រាន់តែបង្ហាញជាឧទាហរណ៍ប៉ុណ្ណោះ ។ នាយកសាលា គួរតែសរសេរសំណើសុំដោយមានការគាំទ្រពិបុគ្គលិក ខេប ដើម្បីកំណត់ពីថវិកាសម្រាប់ផ្សារប្រឌិត ។ សំណើសុំនេះ ត្រូវតែធ្វើការប្រជុំពិភាក្សាជាមួយប្រធានកម្រងដែលជាអ្នកដកថវិកាពី ខេប ។

**<u>បញ្ជាក់</u>** : សំណើសុំមិនលើសពី ១២០ ដុល្លា ( **$120.00** )

## 5. <u>តួនាទីរបស់សមាគមសិស្ស</u> :

ចំពោះសាលាដែលបានបង្កើតសមាគមសិស្សហើយ អាចចាប់ផ្តើមជាមួយក្លឹបថ្មីមួយទៀត គឺ ក្លិបផ្សារប្រឌិត ។ សមាជិកនៅក្លឹបផ្សារប្រឌិត ត្រូវបានទទួលការគាំទ្រពីសហគមន៍ និង គ្រូស្ម័គ្រចិត្ត ។ សកម្មភាពផ្សារប្រឌិត ត្រូវត្រួតពិនិត្យតាមដានដោយគ្រូថ្នាក់ទី ៥ និង ថ្នាក់ ទី ៦ ប៉ុន្តែចំពោះសមាជិកក្លឹបផ្សារប្រឌិត និង អ្នកទទួលខុសត្រូវលើផ្នែកណាមួយនៃការងាររបស់គេ ដូចជា ÷

- ❖ ជួយណែនាំសិស្សថ្នាក់ទី ៥ និង ថ្នាក់ទី៦ ដើម្បីអនុវត្តផ្សារប្រឌិត
- ❖ រៀបចំការវាយតម្លៃលើសកម្មភាពផ្សារប្រឌិត

សហគមន៍ ព្រមទាំង គ្រូ ដែលស្ម័គ្រចិត្តត្រូវជួយដល់សមាជិកក្លឹបផ្សារប្រឌិតដើម្បីអនុវត្តន៍សកម្មភាពផ្សារប្រឌិត ។ សមាគមសិស្សអាចរកប្រាក់បាន ៥០៖ ចំពោះការចូលរួមប្រជុំរៀងរាល់សប្តាហ៍ ។

# ឧបសម្ព័ន្ធ A

## ការតម្រង់ទិសដល់គ្រូ និង សហគមន៍

**I. គោលបំណង :**

គ្រូ និង សហគមន៍យល់បានច្បាស់អំពីសកម្មភាពផ្សារប្រឌិត ។

**II. លំនាំបង្រៀន :**

នាយកសាលា ត្រូវពន្យល់ដល់សមាជិកសហគមន៍និងគ្រូថា សាលាកំពុងរៀបចំផែនការសម្រាប់សកម្មភាពផ្សារប្រឌិត ។

ផ្សារប្រឌិត គឺជាសកម្មភាពមួយដែលបានបង្កើតឡើងតាមរយៈសហគមន៍ដែលមានមូលដ្ឋានផ្អែកបំណិនជីវិត ។ នាយកសាលាគួរសួរសំណួរដូចខាងក្រោម ÷

1. តើបំណិនជីវិតមានអ្វីខ្លះក្នុងសាលាយើង ?
2. តើយើងអនុវត្តសកម្មភាពនេះនៅពេលណា ?
3. ហេតុអ្វីបានជាយើងបង្កើតសកម្មភាពបំណិនជីវិតទាំងនេះ ?

ប្រសិនជាចម្លើយពុំបានបង្ហាញដោយសិក្ខាកាមនោះទេ នាយកសាលាគួរតែបង្ហាញនូវចំណុចដូចខាងក្រោមដោយសួរសំណួរ ÷

1. ការកាត់សក់ , ជួសជុលកង់ , ប្រគុំភ្លេង , កាត់ដេរ , ចំអិនអាហារ . . . ។ ល ។ ( ក្នុងសាលានីមួយ ៗ មានបំណិនខុស ៗ គ្នា ) ។
2. សកម្មភាពទាំងនេះនិងចាប់ផ្តើមក្នុងរយៈពេល ១០ សប្តាហ៍ ទៅ ១៥ សប្តាហ៍ ដោយចាប់ផ្តើម ក្នុងខែ កុម្ភៈ ។ ថ្នាក់ទី ៥ និង ថ្នាក់ទី ៦ មានឱកាសទម្លាប់ខ្លួនរបស់គេជាមួយបំណិនផ្សេង ៗ កម្មវិធីបំណិនជីវិត ។

នាយកសាលា ត្រូវពន្យល់ថា នៅក្នុងកម្មវិធីបំណិនជីវិត សិស្សថ្នាក់ទី ៥ និង ថ្នាក់ទិ ៦ មានឱកាសដើម្បីទម្លាប់ខ្លួនរបស់គេជាមួយបំណិនផ្សេង ៗ ក្នុងរយៈពេល ១០ សប្តាហ៍ ទៅ ១៥ សប្តាហ៍ ។ សកម្មភាពផ្សារប្រឌិត និងកើតឡើងនៅសប្តាហ៍ទី ១១ និង សប្តាហ៍ទី ១៤ ។ ក្នុងសប្តាហ៍ទាំង ២ នេះ សិស្សមួយចំនួនអាចធ្វើជាអ្នកលក់ និង ខ្លះទៀត អាចធ្វើជាអ្នកទិញ ។ បញ្ហានេះអាស្រ័យទៅតាមចំនួនសិស្សដែលមាននៅថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ។ សិស្សម្នាក់ ៗ មានឱកាសរកប្រាក់ ( ប្រាក់សិប្បនិម្មិត) ដោយមករៀននិង ធ្វើសកម្មភាពផ្សេង ៗ ទៀតក្នុងសាលា ដូចជា សំអាតបន្ទប់រៀន , ដាំផ្កា , ស្រោចផ្កា , ជួយគ្រូ . . . ។ ល ។ សិស្សម្នាក់ ៗ អាចសន្សំចរិការបស់គេ នៅពេលដែលកម្មវិធីបំណិនជីវិតចាប់ផ្តើម ។ សិស្សម្នាក់ ៗ មានសៀវភៅសន្សំប្រាក់ដែលត្រូវធ្វើការពិតដោយគ្រូប្រចាំថ្នាក់ក្នុង ១ សប្តាហ៍ម្តង ។

នាយកសាលា អាចសាកសួរគ្រូ ព្រមទាំង សហគមន៍ ពិចារណាពីរបៀបរកប្រាក់របស់សិស្ស តាមរយៈធ្វើសកម្មភាពអ្វី

ខ្លះទៀត ដោយសរសេរចម្លើយរបស់គេលើក្ដារខៀន ។

នាយកសាលា គប្បីពន្យល់ថា បន្ទាប់ពីសកម្មភាពបំណិនជីវិតត្រូវបានបញ្ចប់ និង មានផ្សារប្រឌិតកើតឡើង ។ ដូច្នេះ សិស្សមានឱកាសដើម្បីរៀបសេវាលក់ដូរ ដែលគេបានរៀនរួចពីផ្នែកបំណិនជីវិត ឬ ពីផ្នែកគេហកិច្ច មានដូចជា : កាត់សក់ ភ្លេងបុរាណ , កាត់ដេរ , ជួសជុលកង់ , លក់អាហារ . . . ។ល ។ ម្យ៉ាងទៀត ពួកគេអាចលក់វត្ថុផ្សេង ៗ ដែលបានផលិតដោយខ្លួនឯង ឬ ពួកគេអាចផ្ដល់សេវាកម្មមួយចំនួន ដែលផ្ដល់ពីសាលារៀន ដូចជា : ការបើកភោជនីយដ្ឋាន , បញ្ចាំងវីដេអូ គំនូរ , ល្បែងល្បងប្រាជ្ញ ( សកម្មភាពគិតដោយវិភាគ និង ច្នៃប្រឌិត ) ។

នាយកសាលា សួរសំណួរដូចខាងក្រោម ÷

តើការអនុវត្តសកម្មភាពផ្សារប្រឌិតមានប្រយោជន៍អ្វីខ្លះសម្រាប់សិស្ស ?

**ចម្លើយ** :

1. ផ្សារប្រឌិត អាចបង្កលក្ខណៈដល់សិស្សអោយទទួលខុសត្រូវជំនាញខ្លះ ៗ ដូចជា : ការទិញ , ការលក់ , រាប់ប្រាក់ កំណត់អាទិភាពក្នុងការចាយប្រាក់របស់គេ , តថ្លៃ , ដាក់តម្លៃទំនិញបានសមស្រប , ប្រកួតប្រជែង . . . ។ល ។
2. ផ្អែកតាមបទពិសោធន៍នេះសិស្សអាចធ្វើការសម្រេចចិត្តបានសមស្របអំពីការងារដែលគេចង់បន្តនៅពេលអនាគត
3. សិស្សទទួលបាននូវចំណេះដឹងជាមូលដ្ឋានពីសេដ្ឋកិច្ចទីផ្សារ
4. សិស្សចេះប្រើគំនិតគិតដោយវិភាគ និង ច្នៃប្រឌិត
5. ទាក់ទាញសិស្សមករៀនទៀងទាត់
6. សិស្សចេះជួយគ្នាទៅវិញទៅមក
7. សិស្សមានទម្លាប់ចេះទទួលខុសត្រូវលើការងាររបស់ខ្លួន
8. សិស្សបានអនុវត្តជាក់ស្ដែងពីអ្វីដែលគេបានរៀនក្នុងកម្មវិធីបំណិនជីវិត ។

នាយកសាលា ត្រូវបិទការប្រជុំ ដោយជំរាបអញ្ជើញសមាជិកសហគមន៍ទាំងអស់មកចូលរួមមើលផ្សារប្រឌិត ។ ឪពុកម្ដាយសិស្សអាចចូលមើលសកម្មភាពផ្សេង ៗ ដោយមិនគិតប្រាក់ លើកលែងតែការលក់អាហារ ។ ពេលនោះ បន្ទប់រៀន , បណ្ណាល័យ , បន្ទប់ធនធានសម្ភារ ត្រូវតែបើកចំហរ ដើម្បីជូនសហគមន៍ស្វែងយល់ ។ នាយកសាលា ត្រូវសួរ ថា តើមានសំណួរអ្វីទៀតទេ ?

# ឧបសម្ព័ន្ធ B

## ការតម្រង់ទិសអំពីសកម្មភាពផ្សារប្រឌិតសម្រាប់សិស្ស

**I. គោលបំណង :**

សិស្សយល់បានច្បាស់អំពីសកម្មភាពផ្សារប្រឌិតនៅក្នុងសាលារៀន ។

**II. លំនាំបង្រៀន :**

បន្ទាប់ពីសកម្មភាពបំណិនជីវិតបានបញ្ចប់ គ្រូត្រូវពន្យល់ថា និងមានផ្សារប្រឌិតកើតឡើង ។

គ្រូសួរសំណួរដូចខាងក្រោម ÷

- ❖ តើអ្នកណាធ្លាប់បានទៅផ្សារខ្លះ ?
- ❖ តើអ្នកបានធ្វើអ្វីខ្លះនៅលើទីផ្សារ ?
- ❖ តើអ្នកបានឃើញអ្វីខ្លះនៅលើទីផ្សារ ?( មានអ្នកលក់ និង អ្នកទិញ , មានតូបលក់ជាច្រើនជាមួយនឹងផលិតផលផ្សេង ៗ គ្នា . . . ) ។

គ្រូនឹងប្រាប់ថា ផ្សារនោះ គឺជាកន្លែងដែលមានមនុស្សមកជួបគ្នា ។ មានអ្នកខ្លះមកទិញ , ហើយមានអ្នកខ្លះទៀតមកលក់ ។ គ្រូនឹងសួរនូវសំណួរដូចខាងក្រោម ÷

- ❖ ហេតុអ្វីបានជាទីផ្សារជាកន្លែងមួយល្អសម្រាប់អ្នកចង់ទិញឥវ៉ាន់ ?( របស់របរ/ផលិតផល ) ។
- ❖ ហេតុអ្វីបានជាទីផ្សារជាកន្លែងមួយល្អសម្រាប់អ្នកចង់លក់ឥវ៉ាន់ ?( របស់របរ/ផលិតផល ) ។

ប្រសិនបើគំនិតរបស់សិស្សមិនចំក្នុងចំណុចខាងលើនេះទេ គ្រូគួរតែដកស្រង់នូវគំនិតដូចតទៅនេះ : ផលិតផលនៅលើទីផ្សារ ជាធម្មតា គឺថោកជាងនៅតាមហាង ។ វាមានផលិតផលជាច្រើនផ្សេង ៗ គ្នាសម្រាប់អ្នកលក់នៅក្នុងកន្លែងតែមួយ ដូច្នេះអ្នកមិនចាំបាច់ធ្វើដំណើរទៅច្រើនកន្លែង ពីព្រោះផ្សារជាកន្លែងមួយសម្រាប់មនុស្សជួបគ្នា និង ទំនាក់ទំនងសង្គម ។

- ❖ នៅក្នុងផ្សារមានអតិថិជនជាច្រើនដែលអ្នកអាចលក់ផលិតផលរបស់អ្នកបាន ។

គ្រូនឹងពន្យល់ថា : យើងអាចសិក្សាអំពីសកម្មភាពជាច្រើន ដែលកើតឡើងនៅលើទីផ្សារ ÷

**1.** យើងអាចសិក្សាអំពីការគ្រប់គ្រងថវិកា ដូចជា : ការទិញ , ការលក់ , ការគិតលុយ , ការតថ្លៃ , ការកំណត់តម្លៃត្រឹមត្រូវសម្រាប់ផលិតផល និង ការប្រកួតប្រជែងគ្នា ។ល ។ គ្រូត្រូវសួរសំណួរដូចខាងក្រោម ÷

- ❖ ហេតុអ្វីបានជាតម្លៃផលិតផលមិនថ្លៃពេក ?

**ចម្លើយ** : ប្រសិនបើថ្លៃខ្ពស់ពេក គ្មាននរណាចង់ទិញផលិតផលរបស់អ្នកឡើយ ។

គ្រូត្រូវសួរសំណួរដូចខាងក្រោម ÷

❖ ហេតុអ្វីបានជាតំលៃផលិតផលមិនថោកពេក ?

**ចម្លើយ** : ប្រសិនបើលក់ថោកពេក ( ថ្លៃទាបពេក ) អ្នកមិនអាចរកប្រាក់ចំណេញបានឡើយ ។

តម្លៃលនៃផលិតផលគួរតែត្រឹមត្រូវ ។ ប្រសិនបើតម្លៃលទាបពេកនោះ និង ទទួលលុយបានតិចសម្រាប់ការចាយវាយទៅលើជីវភាពរបស់អ្នក ។ តម្លៃ គឺត្រូវកំណត់ផងដែរដោយអ្នកលក់ ។ ខណៈដែលអ្នកដាក់តម្លៃខ្ពស់ជាងគូប្រជែងរបស់អ្នកនោះគ្មាននរណានឹងទិញផលិតផលរបស់អ្នកទេ គេច្បាស់ជានឹងទៅទិញផលិតផលគូប្រជែងរបស់អ្នកជាក់ជាមិនខាន ។

2. អ្នកអាចសិក្សាអំពីជំនួញផ្សេង ៗ ដែលមនុស្សម្នាធ្វើនៅលើទីផ្សារ ។ ប្រហែលជាអ្នកអាចមើលផលិតផលមួយចំនួននៅលើទីផ្សារដែលអ្នកចង់ធ្វើពេលអនាគត ។

គ្រូនឹងសួរនូវសំណួរដូចខាងក្រោម ÷

- នៅតាមទីផ្សារ តើប្អូនចូលចិត្តប្រកបរបរអ្វីជាងគេ ?
- ហេតុអ្វីបានជាប្អូនចូលចិត្តមុខរបរនោះ ?

គ្រូត្រូវពន្យល់ថា សាលារៀននឹងរៀបចំផ្សារប្រឌិតមួយ ។ ផ្សារប្រឌិតនេះនឹងកើតឡើងបន្ទាប់ពីកម្មវិធីបំណិនជីវិតត្រូវបានបញ្ចប់ ។

នៅក្នុងសប្តាហ៍ទី ១១ និងសប្តាហ៍ទី ១៤ សិស្សមួយចំនួនក្នុងចំណោមសិស្សទាំងអស់នឹងអាចជាអ្នកលក់ ហើយមួយចំនួនទៀតនឹងអាចជាអ្នកទិញ ។ បញ្ហានេះ អាស្រ័យទៅលើសិស្ស ដែលមាននៅក្នុងថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ។

សិស្សទាំងអស់ អាចផ្តល់សេវាកម្មទាំងឡាយ ដែលពួកគេបានសិក្សាក្នុងកម្មវិធីបំណិនជីវិត និង គេហកិច្ច ដូចជា : ការកាត់សក់ , ភ្លេងបុរាណ , ការកាត់ដេរ . . . ។ល ។ ពួកគេអាចលក់នូវផលិតផលទាំងឡាយដែលសាលារៀនបានទិញ ឬ ពួកគេអាចផ្តល់នូវសេវាកម្មទាំងឡាយដែលចាត់ចែងដោយសាលា ដូចជា : ផ្នែកម្ហូបអាហារនៅក្នុងភោជនីយដ្ឋាន , ការទស្សនាវីដេអូ គំនូរជីវចល , គំនូរ និង ល្បែងល្បងប្រាជ្ញា ។

គ្រូពន្យល់ថា លុយអាចត្រូវបានសន្សំដោយការចាប់ផ្តើមពីចំណុចដំបូងនៃកម្មវិធីបំណិនជីវិត ។ សិស្សម្នាក់ ៗ នឹងបង្កើតនូវកូនសៀវភៅសន្សំលុយតូចមួយ សម្រាប់កត់ត្រាចំនួនប្រាក់របស់ខ្លួនរៀងរាល់សប្តាហ៍ ឬ គ្រូអាចកត់ត្រានូវចំនួនលុយដែលពួកគេបានរក ។ បន្ទាប់ពីរយៈពេល ១០ សប្តាហ៍ សិស្សអាចដកលុយរបស់ពួកគេយកមកចាយនៅថ្ងៃបើកផ្សារប្រឌិត ។ សិស្សទាំងអស់អាចរកលុយតាមមធ្យោបាយដូចខាងក្រោម ÷

❖ **សកម្មភាពរៀន** :

1. ពេលដែលសិស្សមានវត្តមានជារាល់រៀងថ្ងៃ សិស្សអាចសន្សំលុយ ៥០ រៀល ក្នុងមួយថ្ងៃ ។ ក្នុងមួយសប្តាហ៍ សិស្សម្នាក់អាចសន្សំលុយបាន ២៥០ រៀល ជាអតិបរិមា ពីព្រោះថ្ងៃព្រហស្បតិ៍មិនមែនជាថ្ងៃរៀនទេ ។
2. ក្រុមនៅក្នុងថ្នាក់រៀននីមួយ ៗ ដែលសិស្សបានសហការល្អប្រសើរជាមួយគ្នាទៅវិញទៅមក ( គ្រូអាចផ្តល់រង្វាន់លើក

ទឹកចិត្ត ៥០ រៀល ដល់សមាជិកម្នាក់ ៗ

3. រក្សាអនាម័យខ្លួនប្រាណបានល្អ ឬ ថែរក្សាសៀវភៅសិក្សា . . . ។ ល ។

❖ **ធ្វើសកម្មភាពជាក់ស្តែងនៅក្នុងសាលារៀន** :

1. ការសំអាត : សិស្សអាចរកចំណូល ៥០ រៀល ជារៀងរាល់ពេលក្នុងការសំអាតបរិស្ថានសាលា , បន្ទប់រៀន ឬ បង្គន់ ។
2. ការថែទាំសួន : សិស្សអាចរកចំណូលបាន ៥០ រៀល ជារៀងរាល់ពេលក្នុងការជួយសំអាត និង ថែទាំសួន ។
3. ការជួយគ្រូ : សិស្សដែលជួយគ្រូ អាចរកលុយបាន ៥០ រៀល នៅពេលដែលគេជួយរក ឬ ជួយផលិតសម្ភារក្នុងការរៀន និង បង្រៀន ។

គ្រូសួរសិស្ស ប្រសិនបើពួកគេមានគំនិតផ្សេងទៀតទៅលើ ការរកលុយក្រដាស គ្រូត្រូវសរសេរគំនិតទាំងនោះនៅលើក្តារខៀន ។

សិស្សម្នាក់ ៗ ត្រូវបង្កើតសៀវភៅសន្សំប្រាក់មួយដូចខាងក្រោមនេះ ÷

| ថ្ងៃខែឆ្នាំ | ពិពណ៌នាពីសកម្មភាពដែលបានធ្វើដោយសិស្ស | ចំណូល | ចំណាយ | សមតុល្យ | ហត្ថលេខារបស់គ្រូ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ពេលដែលសិស្សរកប្រាក់បាន គេត្រូវបំពេញតារាងខាងលើ ដោយចុះថ្ងៃ ខែ សកម្មភាព ដែលបានធ្វើ ប្រាក់ចំណូល ប្រាក់ចំណាយ សមតុល្យ ។ គ្រូប្រចាំថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ត្រូវចុះហត្ថលេខាលើសៀវភៅសន្សំប្រាក់របស់សិស្ស ១ សប្តាហ៍ម្តង ។ ត្រូវរកករណីសិក្សាអោយសិស្សអាន ។

# ករណីសិក្សា

សុខាមានអាយុ ១១ ឆ្នាំ កំពុងរៀននៅថ្នាក់ទី ៥ ។ ១០ សប្តាហ៍កន្លងមកនេះ នាងបានទទួលកូនសៀវភៅសន្សំប្រាក់មួយ ។ គ្រូបានពន្យល់យ៉ាងច្បាស់លាស់ពីមធ្យោបាយដែលនាងសន្សំប្រាក់បាន ។ រៀងរាល់សប្តាហ៍សិស្សបានកត់ត្រានូវចំនួនប្រាក់ដែលបានសន្សំទុកក្នុងរយៈពេល ១០ សប្តាហ៍នោះ ។ គ្រូបានត្រួតពិនិត្យមើលនូវរាល់បណ្តាសៀវភៅសន្សំប្រាក់នីមួយ ៗ ហើយចុះហត្ថលេខា ដើម្បីប្រាកដថា ការសន្សំប្រាក់របស់គេមានលក្ខណៈត្រឹមត្រូវ ។

សុខា គឺជាសិស្សដែលមានវត្តមានជារៀងរាល់ថ្ងៃ ក្នុងរយៈពេល ១០ សប្តាហ៍ កន្លងទៅ ។ នាងបានជួយគ្រូរបស់នាង ២ ដងផងដែរ ដូចជា : ការសំអាតថ្នាក់រៀន និង កិច្ចការថែទាំសួនផ្កានៅមុខថ្នាក់រៀន ។ គ្រូរបស់នាងបានផ្តល់រង្វាន់លើកទឹកចិត្តដល់ក្រុមរបស់នាង ពីព្រោះសិស្សទាំងអស់ក្នុងក្រុមរបស់នាងបានសហការគ្នាយ៉ាងល្អប្រសើរ ។ សុខាសន្សំប្រាក់បានសរុបចំនួន ២,៦៥០ រៀល ។ ក្នុងរយៈពេល ២ សប្តាហ៍នៃផ្សារប្រឌិត នាងបានត្រឹមតែទិញប៉ុណ្ណោះ មិនបានលក់ផលិតផល និង របស់របរអ្វីទេ ។ នាងមិនចង់ចំណាយប្រាក់របស់នាងទាំងអស់ក្នុងរយៈពេល ១ សប្តាហ៍ទេ រឿងនេះហើយដែលជាហេតុធ្វើអោយនាងដកប្រាក់ ១,៦០០ រៀល ពីគណនីសន្សំរបស់នាង ។ មានសកម្មភាពចំនួន ៧ នៅក្នុងការបើកផ្សារប្រឌិត គឺ ÷

- កាត់សក់ ( តម្លៃ ៤០០ រៀល )
- ការស្តាប់ភ្លេងប្រពៃណី ( តម្លៃ ២០០ រៀល )
- ការជួសជុលកង់ ( តម្លៃ ៤០០ រៀល )
- ភោជនីយដ្ឋាន ( តម្លៃ ៨០០ រៀល )
- គំនូរ ( តម្លៃ ៣០០ រៀល )
- ល្បែងល្បងប្រាជ្ញា ( តម្លៃ ៣០០ រៀល )
- មើល វីដេអូ គំនូរជីវចល ( តម្លៃ ៤៥០ រៀល )

សុខាចូលចិត្តសកម្មភាពទាំងអស់នេះខ្លាំងណាស់ ប៉ុន្តែនាងគ្មានលុយគ្រប់គ្រាន់ដើម្បីអនុវត្តនូវសកម្មភាពទាំងអស់នេះបានទេ ។ នៅក្នុងសប្តាហ៍ទី ១ នៃផ្សារប្រឌិត សុខាចង់ មើលវីដេអូ , កាត់សក់ និង គូរគំនូរ ។ នៅសប្តាហ៍ទី ២ នាងចង់ញ៉ាំអាហារនៅឯភោជនីយដ្ឋាន , ចង់លេងល្បែងល្បងប្រាជ្ញា និង ស្តាប់ភ្លេងប្រពៃណី ។

## សំណួរពិភាក្សា :

**1)** តើមានប្រាក់ចំនួនប៉ុន្មានដែលសុខាបានសន្សំរាល់វត្តមាននៃសប្តាហ៍នីមួយ ៗ ?

**ចម្លើយ** : ៥ ថ្ងៃ x ៥០៛ = ២៥០៛

**2)** តើមានប្រាក់ចំនួនប៉ុន្មានដែលសុខាសន្សំបានពីការជួយកិច្ចការគ្រូ ?

**ចម្លើយ** : ២ ដង x ៥០៛ = ១០០៛

**3)** តើមានប្រាក់ចំនួនប៉ុន្មាន ដែលសុខាបានសន្សំចំពោះការឈ្នះរង្វាន់លើការសហការបានល្អប្រសើរនោះ ?

**ចម្លើយ** : ១ ដង x ៥០៛ = ៥០៛

**4)** សូមបំពេញតារាងខាងក្រោមចំពោះការសន្សំប្រាក់របស់សុខា ចំពោះកាលបរិច្ឆេទបំពេញថ្ងៃណាក៏បាន ។

| ថ្ងៃខែឆ្នាំ | ពិពណ៌នាពីសកម្មភាពដែលសិស្សបានធ្វើ | ប្រាក់ចំណូល | ប្រាក់ចំណាយ | សមតុល្យ | ហត្ថលេខារបស់គ្រូ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## សៀវភៅសន្សំប្រាក់របស់សិស្សមានលក្ខណះដូចខាងក្រោម ÷

| ថ្ងៃខែឆ្នាំ | ពិពណ៌នាពីសកម្មភាព ដែលសិស្សបានធ្វើ | ប្រាក់ចំណូល | ប្រាក់ចំណាយ | សមតុល្យ | ហត្ថលេខា របស់គ្រូ |
|---|---|---|---|---|---|
| ១០/៥/០៣ | វត្តមាន ៥ ថ្ងៃ x ៥០៛ | ២៥០៛ | | ២៥០៛ | |
| ១៧/៥/០៣ | វត្តមាន | ២៥០៛ | | ៥០០៛ | |
| ២៤/៥/០៣ | វត្តមាន | ២៥០៛ | | ៧៥០៛ | |
| ៣១/៥/០៣ | វត្តមាន | ២៥០៛ | | ១,០០០៛ | |
| ៧/៦/០៣ | វត្តមាន | ២៥០៛ | | ១,២៥០៛ | |
| ១៣/៦/០៣ | វត្តមាន | ២៥០៛ | | ១,៥០០៛ | |
| ២០/៦/០៣ | វត្តមាន | ២៥០៛ | | ១,៧៥០៛ | |
| ២០/៦/០៣ | ជួយកិច្ចការគ្រូ | ៥០៛ | | ១,៨០០៛ | |
| ២៧/៦/០៣ | វត្តមាន | ២៥០៛ | | ២,០៥០៛ | |
| ៤/៧/០៣ | វត្តមាន | ២៥០៛ | | ២,៣០០៛ | |
| ៤/៧/០៣ | ជួយកិច្ចការគ្រូ | ៥០៛ | | ២,៣៥០៛ | |
| ១១/៧/០៣ | វត្តមាន | ២៥០៛ | | ២,៦០០៛ | |
| ១១/៧/០៣ | រង្វាន់លើកទឹកចិត្តសំរាប់ក្រុម | ៥០៛ | | ២,៦៥០៛ | |

**កំណត់សំគាល់** : សៀវភៅសន្សំប្រាក់ ត្រូវបំពេញជារៀងរាល់សប្តាហ៏ មានន័យថា ប្រសិនបើការសន្សំដំបូងបានបញ្ចូលនៅថ្ងៃទី ១០ ខែ ៥ ឆ្នាំ ២០០៣ ថ្ងៃបន្ទាប់មកទៀត គឺបញ្ចូលនៅថ្ងៃទី ១៧ ខែ ៥ ឆ្នាំ ២០០៣ ។

5) តើសុខាមានប្រាក់គ្រប់គ្រាន់ ដើម្បីធ្វើសកម្មភាពទាំងអស់នេះដូចដែលនាងចង់ធ្វើនោះបានឬទេ ?

**ចម្លើយ** : សុខាមានប្រាក់គ្រប់គ្រាន់ ។

# ករណីសិក្សា

ដារាមានអាយុ ១២ ឆ្នាំ ជាសិស្សថ្នាក់ទី ៥ ។ វាសន្សំប្រាក់បាន ៣,០០០៛ ក្នុងពេល ១០ សប្តាហ៍កន្លងទៅនេះ ។ វាចង់បើកភោជនីយដ្ឋានមួយនៅឯទីផ្សារប្រឌិត ។ វាត្រូវការប្រាក់ចំនួន ១៥,០០០៛ សម្រាប់ទិញសម្ភារ និង អាហារពីសាលា ។ វាសំរេចចិត្តស្វែងរកសិស្ស ២ នាក់ ដែលបានរៀនដាំស្ល ពួកគេ ៣ នាក់ បានដាក់ប្រាក់បញ្ចូលគ្នាមានចំនួន ៨,០០០៛ ។ ប្រាក់ទាំងអស់នេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដូច្នេះទាំង ៣ នាក់ បានពិភាក្សាជាមួយគ្រូ ប្រចាំថ្នាក់ទី ៥ ។ គ្រូបានអោយពួកគេខ្ចីប្រាក់ចំនួន ៧,០០០៛ ដោយយកប្រាក់ការ ១០% ។ ពួកគេទាំង ៣ នាក់ បានសំរេចចិត្ត ធ្វើនំបញ្ចុក ពីព្រោះពួកគេដឹងអំពីរបៀបធ្វើនំនេះដែលមានរសជាតិឆ្ងាញ់ ។ ដារា និង មិត្តរបស់គេ បានពិភាក្សាថា តើអ្នកណាជាអ្នកចំអិន ? អ្នកណាជាអ្នករៀបចំអាហារ ? ហើយអ្នកណាជាអ្នកលាងចាន ពួកគេដាក់ឈ្មោះនៃភោជនីយដ្ឋានរបស់ខ្លួនថា " **នាគបី** " ។ ដារា និង មិត្តរបស់គេបានរៀបចំសម្ភារទាំងអស់ ដូចជា : ឆ្នាំង , ចង្ក្រាន , ធ្យូង , ចាន និង កាំបិតគ្រប់ប្រភេទ ។ល ។ មុនថ្ងៃដែលពួកគេធ្វើផ្សារប្រឌិតនេះឡើង ។ ផ្សារប្រឌិត ចាប់ផ្តើមឡើងនៅម៉ោង ៨:០០ ព្រឹក ប៉ុន្តែចំពោះការចំអិនវិញ ពួកគេចាប់ផ្តើមតាំងពីព្រលឹមមកម្លេះ ។ ជាសំណាងល្អ ម្តាយពួកគេបានមកជួយនៅពេលព្រឹក ដូច្នេះនៅម៉ោង ៨:០០ ព្រឹក ពួកគេបានរៀបចំអាហាររួចជាស្រេច ( នំបញ្ចុក ១ ចាន តម្លៃ ៨០០៛ ) ។

សរុបសិស្សទាំងអស់ដែលមកញុំាចំនួន ៣០ នាក់ ។ សិស្សទាំង ៣ នាក់ បានជួយសំអាតទីកន្លែងក្នុងភោជនីយដ្ឋាន ហើយពួកគេបានបែងចែកប្រាក់គ្នា ។ ពួកគេត្រូវសងប្រាក់ទៅអោយសាលារៀនវិញ ។ ពេលនេះសិស្សទាំងអស់ចង់ទទួលប្រាក់ដែលពួកគេបានដាក់ទុនក្នុងភោជនីយដ្ឋានត្រឡប់មកវិញ ។ ឧទាហរណ៍ : ដារា បានទទួលប្រាក់ ៣,០០០៛ របស់វាត្រឡប់មកវិញ ហើយប្រាក់ដែលនៅសេសសល់ត្រូវបានគេបែងចែកស្មើ ៗ គ្នាក្នុងចំណោមសិស្សទាំង ៣ នាក់ ។

## សំណួរពិភាក្សា :

1) តើប្រាក់ចំនួនប៉ុន្មានដែលសិស្សទាំង ៣ នាក់ ត្រូវចំណាយសងទៅសាលារៀនវិញ ?

**ចម្លើយ** : ចំនួនប្រាក់ដែលបានខ្ចី ៧,០០០៛ និង ៧០០៛ ( ១០% ប្រាក់ការ ) = ៧,៧០០៛

2) តើភោជនីយដ្ឋាននេះបានទទួលប្រាក់ចំនួនប៉ុន្មានពីអតិថិជន ?

**ចម្លើយ** : សិស្ស ៣០ នាក់ x ៨០០៛ សម្រាប់នំបញ្ចុក ១ ចាន = ២៤,០០០៛

3) តើប្រាក់នៅសល់ប៉ុន្មាន បន្ទាប់ពីសិស្សទាំងអស់បានទូទាត់លើការបណ្តាក់ទុនរបស់ពួកគេ ?

**ចម្លើយ** : ប្រាក់ចំណូលបានចំនួន ២៤,០០០៛ - ( ប្រាក់ដែលបានខ្ចី + ប្រាក់ការ) ៧,៧០០៛ - ប្រាក់ដែលបានបណ្តាក់ទុន ៨,០០០៛ = ៨,៣០០៛ ជាប្រាក់ដែលនៅសល់ ។

**4)** នៅចុងបញ្ចប់ តើសិស្សម្នាក់ ៗ បានទទួលប្រាក់ចំណេញប៉ុន្មាន ?

**<u>ចម្លើយ</u> :** ៨,៣០០៛ គឺត្រូវបានបែងចែកទៅលើសិស្ស ៣ នាក់ ម្នាក់ ៗ បាន ២,៧០០៛ ( ២០០៛ ទៀតជាប្រាក់សស់ ) ។

គ្រូត្រូវពន្យល់ថា សិស្សទាំងអស់ត្រូវចាប់ផ្តើមពិចារណា តើមុខរបរអ្វីដែលគេចង់ធ្វើ ។ ពេលក្រោយយើងរៀបចំធ្វើការបោះឆ្នោត ដើម្បីកំណត់ថា តើសិស្សណាខ្លះធ្វើជាអ្នកលក់ ។ គ្រូត្រូវសួរបញ្ជាក់ទៅសិស្សទៀតថា តើមានសំណួរឬទេ ?

# ឧបសម្ព័ន្ធ C

## ការអនុវត្តសកម្មភាពផ្សារប្រឌិត

**I. គោលបំណង :**

សិស្សនៅថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ÷

- យល់អំពីវិធីរៀបចំផ្សារប្រឌិត
- ចេះជ្រើសរើសសកម្មភាពដែលគេចង់ធ្វើក្នុងផ្សារប្រឌិត ។

**II. លំនាំបង្រៀន :**

គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ត្រូវបង្រៀនសិស្សរបស់ខ្លួនអំពីការអនុវត្តផ្សារប្រឌិត ដោយពន្យល់ថា ក្នុងមេរៀននេះ យើងនឹងសិក្សាអំពីការរៀបចំផ្សារប្រឌិត ។

គ្រូត្រូវសួរសំណួរដូចខាងក្រោម ÷

1) តើផ្សារប្រឌិត កើតឡើងមុន ឬ ក្រោយសកម្មភាពបំណិនជីវិត ?

( **ចម្លើយ** : ក្រោយសកម្មភាពបំណិនជីវិត ) ។

2) តើការបើកផ្សារប្រឌិត មានរយៈពេលប៉ុន្មានថ្ងៃ ? នៅពេលណា ? សិស្សធ្វើអ្វីខ្លះ ?

( **ចម្លើយ** : សាលានឹងរៀបចំផ្សារប្រឌិតនៅរាល់ថ្ងៃព្រហស្បតិ៍ រយៈពេលតែ ២ សប្តាហ៍ ក្នុងសប្តាហ៍ទី ១ សិស្សមួយចំនួនធ្វើជាអ្នកលក់ ឯសិស្សមួយចំនួនទៀតធ្វើជាអ្នកទិញ ។ ក្នុងសប្តាហ៍ទី ២ សិស្សនឹងផ្លាស់ប្តូរសកម្មភាពគ្នា ) ។

3) តើសិស្សរកប្រាក់មកពីណាសម្រាប់ប្រើប្រាស់ក្នុងទីផ្សារប្រឌិត ?

( **ចម្លើយ** : សិស្សទាំងអស់អាច " រកកំរៃ " ដោយទទួលប្រាក់ក្រដាស សម្រាប់ចូលរៀន រៀងរាល់ថ្ងៃ ជួយសម្អាតសាលារៀន ជួយគ្រូ ជួយថែទាំសួនផ្កា ។ល។ សិស្សអាចចាប់ផ្តើមសន្សំប្រាក់របស់ខ្លួននៅពេលសកម្មភាពបំណិនជីវិតចាប់ផ្តើម ។

គ្រូត្រូវពន្យល់ប្រាប់សិស្សពីមធ្យោបាយផ្សេង ៗ ដើម្បីរកប្រាក់ និង ការចំណាយប្រាក់នៅថ្ងៃបើកផ្សារប្រឌិត ។ គ្រូត្រូវពន្យល់ផងដែរថា សាលាមានរៀបចំកន្លែងសម្រាប់សកម្មភាពនីមួយ ៗ ប៉ុន្តែចំពោះសម្ភារសិស្សត្រូវរៀបចំដោយខ្លួនឯងក្រោមការជួយជ្រោងជ្រែងរបស់គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ព្រមទាំង នាយកសាលា ។

**1) បំណិនដែលសិស្សបានរៀនក្នុងសកម្មភាពបំណិនជីវិត :**

- <u>ការកាត់សក់</u> : សិស្សអាច " រកកំរៃដោយកាត់សក់ " ។ សិស្សត្រូវតែជួលសម្ភារឧបករណ៍កាត់សក់ដែលគេត្រូវការក្នុងតម្លៃ ៨០០ រៀល ។
- ឧបករណ៍ភ្លេងបុរាណ : សិស្សត្រូវតែ " ជួល " ឧបករណ៍ភ្លេងបុរាណពីសាលារៀន តម្លៃ ១,៥០០ រៀល ។

- ការកាត់ដេរ : សិស្សអាចលក់ផលិតផល ដូចជា : ម៉ាស់ កែប សម្រាប់លុបក្តារខៀន ស្រោមដៃ មួក និង កន្សែងពានា ។ល ។ សាលារៀននឹងផ្តល់សម្ភារទាំងអស់នោះដែលចាំបាច់សម្រាប់ផលិតសម្ភារទាំងនោះ ។ សិស្សអាចធ្វើនៅផ្ទះរបស់ខ្លួន ឬ ក្នុងពេលរៀនសកម្មភាពបំណិនជីវិត ។
- ជួសជុលកង់ : សិស្សអាចជួសជុលកង់របស់សិស្សដទៃទៀត ឬ មាតាបិតាសិស្សដែលមកទស្សនកិច្ចផ្សារប្រឌិត ។ សិស្សត្រូវជួលឧបករណ៍សម្រាប់ជួសជុលក្នុងតំលៃ ៨00 រៀល ។
- ហាងលក់បាយ : សិស្សនឹងធ្វើម្ហូប និង បំរើម្ហូបអោយសិស្សដទៃទៀត ។ សិស្សត្រូវតែជួលឧបករណ៍ធ្វើម្ហូប មាន : ឆ្នាំង , ចាន , សម , ស្លាបព្រា . . . មួយសម្រាប់តម្លៃ ២0,000 រៀល ។

2) **សកម្មភាពផ្សេង ៗ ទៀត** :

- គូរគំនូរ : សិស្សដែលរៀបចំសកម្មភាពនេះត្រូវតែជួលសម្ភារពីសាលា ដូចជា : ក្រដាសរ៉ាម A៤ , ថ្នាំលាប និង ការ ក្នុងតម្លៃ ២,000 រៀល ។
- បន្ទប់ល្បែងល្បងប្រាជ្ញា : សិស្សរៀបចំសកម្មភាពនេះត្រូវតែជួលសម្ភារទាំងអស់ក្នុងតម្លៃ ២,000 រៀល ។
- ការបញ្ចាំង វីដេអូ តុក្កតា : សិស្សរៀបចំសកម្មភាពនេះត្រូវតែជួលវីដេអូពីសាលាក្នុងតំលៃ ២0,000 រៀល ។
- លក់ផលិតផលផ្សេង ៗ : សិស្សអាចលក់ភេសជ្ជៈ ឬ នំ ផ្សេង ៗ ។ សិស្សរៀបចំសកម្មភាពនេះត្រូវតែទិញ ទំនិញពីសាលារៀនក្នុងតម្លៃ ១៥,000 រៀល ។

គ្រូគួរតែបញ្ជាក់ម្តងទៀតថា សិស្សត្រូវតែប្រើប្រាស់ លុយក្រដាស របស់ខ្លួនរៀបចំសេវាកម្មរបស់គេ ។ ធ្វើដូចនេះសិស្ស អាចយល់ថា ដើម្បីបានចំណេញប្រាក់ អ្នកលក់ត្រូវតែចំណាយទុនជាមុន ដើម្បីទិញសម្ភារ ឬ ជួលកន្លែង ។

**ករណីពិសេស** : សម្រាប់សកម្មភាពកាត់ដេរ សិស្សមិនចាំបាច់ចំណាយទុនទេ ។ ដោយសារសិស្សត្រូវតែចំណាយពេលវេលា ជាច្រើន ដើម្បីផលិតសម្ភារសម្រាប់លក់ ។

គ្រូបញ្ជាក់ម្តងទៀតអំពីការចំណាយប្រាក់របស់គេ ដើម្បីធ្វើសកម្មភាពនីមួយ ៗ ខាងក្រោម ÷

| | |
|---|---|
| ការកាត់សក់ | ៤00 រៀល |
| ស្ពាប់ភ្លេង | ៤00 រៀល |
| ជួសជុលកង់ | ៤00 រៀល |
| គូរគំនូរ | ៤00 រៀល |
| ល្បែងល្បងប្រាជ្ញា | ៤00 រៀល |
| ម្ហូបអាហារ | ៤00 រៀល |
| មើលវីដេអូ | ៤00 រៀល |
| ផលិតផលផ្សេង ៗ | តម្លៃអាចប្រែប្រួល |

**<u>សំគាល់</u>** : ចំពោះតម្លៃសកម្មភាពនីមួយ ៗ ខាងលើ គ្រាន់តែផ្ដល់ជាឧទាហរណ៍ប៉ុណ្ណោះ ។ ហេតុនេះតម្លៃគួរតែបានកំណត់ទៅតាមស្ថានភាពជាក់ស្ដែង ។

**3) <u>ការប្រមូលប្រាក់ដើម្បីរៀបចំសេវាលក់ដូរ</u>** :

សកម្មភាពដូចជាការរៀបចំហាងលក់បាយ ឬ ការបញ្ចាំង វីដេអូ ទាមទារការចំណាយទុនជាច្រើន ។ គ្រូសួរថា ប្រសិនជាសិស្សគ្មានប្រាក់ផ្ទាល់ខ្លួនសម្រាប់រៀបចំសកម្មភាពនេះ តើសិស្សអាចរៃអង្គាសប្រាក់តាមវិធីណា ?

**<u>ចម្លើយ</u>** :

១. សហការជាមួយសិស្សដទៃទៀត ដើម្បីរួមបញ្ចូលប្រាក់គ្នា

២. ខ្ចីប្រាក់ពីសាលារៀនដែលគិតការប្រាក់ ១០%

៣. សហការជាមួយសិស្សដទៃទៀត និង ខ្ចីពីសាលារៀន ។

គ្រូគួរតែសរសេរបញ្ជីដូចខាងក្រោមនៅលើក្ដារខៀន ÷

**4) <u>ចំនួនអ្នកលក់ក្នុងសប្ដាហ៍នីមួយ ៗ ឈ្មោះសិស្ស</u>** :

| | សប្ដាហ៍ទី ១ | សប្ដាហ៍ទី ២ |
|---|---|---|
| - ការកាត់សក់<br>( ពី ១ នាក់ ដល់ ៣ នាក់ ) | | |
| - ឧបករណ៍ភ្លេង<br>( ពី ៥ នាក់ ដល់ ៥ នាក់ ) | | |
| - ជួសជុលកង់<br>( ពី ១ នាក់ ដល់ ៣ នាក់ ) | | |
| - គូរគំនូរ<br>( ពី ១ នាក់ ដល់ ៣ នាក់ ) | | |
| - ល្បែងល្បងប្រាជ្ញា<br>( ពី ១ នាក់ ដល់ ៣ នាក់ ) | | |
| - ហាងលក់បាយ<br>( ពី ៣ នាក់ ដល់ ៧ នាក់ ) | | |
| - បញ្ចាំង វីដេអូ<br>( ពី ៣ នាក់ ដល់ ៧ នាក់ ) | | |
| - លក់ផលិតផលផ្សេង ៗ<br>( ពី ១ នាក់ ដល់ ៨ នាក់ ) | | |

គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ គប្បីពន្យល់ថា សិស្សអាចជ្រើសរើសសកម្មភាពណាដែលដែលគេពេញចិត្ត ។ សិស្សម្នាក់ ៗ អាចធ្វើអ្នកលក់បានតែម្តងប៉ុណ្ណោះ ។ សិស្សទាំងអស់ទទួលបានសន្លឹកឆ្នោតម្នាក់ ១ សន្លឹក រួចសរសេរឈ្មោះរបស់គេលើសន្លឹកឆ្នោតនោះ ។ ជាដំបូងគ្រូត្រូវសួរសិស្សថា ប្អូនណាចង់ធ្វើជាជាងកាត់សក់ ។ សិស្សដែលចាប់អារម្មណ៍ក្នុងការកាត់សក់ ត្រូវដាក់សន្លឹកឆ្នោតរបស់ខ្លួនចូលក្នុងប្រអប់ ។ គ្រូត្រូវធ្វើការជ្រើសរើសដោយចាប់យកតែសន្លឹកឆ្នោតចំនួន ៦ សន្លឹក ។ បន្ទាប់មកអានឈ្មោះទាំងនោះដោយសរសេរលើក្តារខៀន ។ម្យ៉ាងទៀត គ្រូត្រូវកំណត់ឈ្មោះសិស្សទាំង ៦ នាក់នោះ សិស្សណាចង់កាត់សក់ក្នុងសប្តាហ៍ទី ១ ឬ ក្នុងសប្តាហ៍ទី ២ ។ គ្រូត្រូវបន្តធ្វើបែបនេះរហូតបញ្ចប់សកម្មភាពនីមួយ ៗ ដែលមាននៅក្នុងផ្សារប្រឌិត ។ ដូច្នេះនៅទីបញ្ចប់ គ្រូអាចរៀបចំបាននូវបញ្ជីឈ្មោះសិស្សដែលធ្វើជាអ្នកលក់នៅសប្តាហ៍ទី ១ និង សប្តាហ៍ទី ២ ។ ចំពោះសាលានីមួយ ៗ គឺបានជ្រើសរើសសកម្មភាពបំណិនជីវិត និង គេហកិច្ច ខុស ៗ គ្នា ។ ដូចនេះ សាលាអាចជ្រើសរើសតែសកម្មភាពណាដែលសិស្សបានរៀននៅក្នុងកម្មវិធី ។ ចំពោះសិស្សដែលមាននៅក្នុងកម្មវិធីបំណិនជីវិត និង គេហកិច្ចត្រូវផ្តល់អាទិភាពអោយគេជ្រើសរើសសកម្មភាពមុនដែលទាក់ទងនឹងបំណិនរបស់គេ ។

**<u>បញ្ជាក់</u>** : ចំពោះភ្លេងបុរាណ ត្រូវរៀបចំនៅជាមួយផ្នែកលក់អាហារ ។ ដូច្នេះ តម្លៃអាហារ ត្រូវបង្កើន ( ប្រហែល ៥០ ៛ បន្ថែមទៀត ) សម្រាប់អ្នកលេងភ្លេងបុរាណ ។

**5) <u>ការគ្រប់គ្រងថវិកា</u> :**

គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ត្រូវពន្យល់ថា នាយកសាលា ជាអ្នកទទួលខុសត្រូវលើផ្នែកថវិកា ។ គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ គឺទទួលខុសត្រូវលើសកម្មភាពផ្សេង ៗ ដើម្បីជួយសិស្សក្នុងការអនុវត្តផ្សារប្រឌិត ។ ចំពោះសិស្សដែលត្រូវការសម្ភារផ្សេង ៗ ឬ ចង់ខ្ចីប្រាក់ពីសាលា គេត្រូវទំនាក់ទំនងជាមួយនាយកសាលា ។ គ្រូត្រូវជួយសិស្សពីរបៀបសរសេរសុំខ្ចីសម្ភារ ឬ ខ្ចីប្រាក់ពីនាយក នៅពេលដែលគេត្រូវការ ។ គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ត្រូវបន្តពន្យល់ទៀតថា ចំពោះការទិញសម្ភារក្រោមតម្លៃ ៥ ដុល្លា នាយកសាលា ត្រូវផ្តល់ថវិកាអោយសិស្សផ្ទាល់តែម្តង ។ ចំពោះការទិញសម្ភារលើសពី ៥ ដុល្លា នាយកសាលាត្រូវអោយ គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ជួយសិស្សក្នុងការទិញសម្ភារ ។ ចំពោះការខ្ចីប្រាក់ពីនាយកសាលា សិស្សត្រូវបំពេញកិច្ចសន្យាដូចខាងក្រោម ÷

**<u>កិច្ចសន្យា</u>**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ : ............................ រៀននៅថ្នាក់ទី : ........ នៃសាលាបឋមសិក្សា .......................... បានខ្ចីប្រាក់ចំនួន : .................. រៀល ពី ....................... ហើយខ្ញុំបាទ-នាងខ្ញុំ សូមសន្យាថា និង ផ្តល់ជូននូវប្រាក់ការចំនួន : ១០% សរុបគឺ : ........................................ រៀល ។

ខ្ញុំបាទ/នាងខ្ញុំ សូមប្រគល់ប្រាក់ដើម+ប្រាក់ការ ជូនទៅសាលាវិញនៅថ្ងៃទី ...... ខែ ......... ឆ្នាំ .........ជាកំណត់ ។

ធ្វើនៅថ្ងៃទី .............. ខែ ............ ឆ្នាំ ......

បានឃើញ និង ពិនិត្យ　　　　　　　　ហត្ថលេខាអ្នកខ្ចី

នាយក

**6) ការអញ្ជើញសហគមន៍ចូលរួមក្នុងសកម្មភាពផ្សារប្រឌិត :**

សិស្សទាំងអស់ ត្រូវទទួលបានក្រដាសរ៉ាម A៤ ១ សន្លឹក ម្នាក់ ដើម្បីសរសេរលិខិតអញ្ជើញឪពុកម្តាយរបស់ខ្លួនមកចូលសកម្មភាពនៅផ្សារប្រឌិត ។ លិខិតអញ្ជើញនេះសិស្សអាចគូររូបភាព ដោយសរសេរបញ្ចូលពត៌មានដូចខាងក្រោម÷

- ការអញ្ជើញចូលរួមផ្សារប្រឌិត
- កន្លែងធ្វើផ្សារប្រឌិត
- កាលបរិច្ឆេទ ការបើកផ្សារប្រឌិត ម៉ោងចាប់ផ្តើម និង ម៉ោងបញ្ចប់ ( ៨:00 ដល់ ១១:00 )
- សកម្មភាពដែលឪពុកម្តាយ អាចមើល ព្រមទាំងធ្វើ ។

សិស្ស ត្រូវយកលិខិតអញ្ជើញនេះទៅផ្ទះ រួចជូនលិខិតនេះទៅឪពុកម្តាយរបស់ខ្លួន ។ គ្រូព្យាយាមជំរុញសិស្សអោយលើកទឹកចិត្តដល់ឪពុកម្តាយរបស់ខ្លួន ដើម្បីអោយពួកគាត់បានចូលរួម ។ ឪពុកម្តាយអាចចូលរួមក្នុងទិផ្សារលើសកម្មភាពផ្សេង ៗ ដោយមិនអស់ប្រាក់ លើកលែងការញាំុអាហារ ។ គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦ ត្រូវពន្យល់សិស្សថា ផ្សារប្រឌិតត្រូវចាប់ផ្តើមនៅម៉ោង ៨:00 ដល់ ១១:00 ។ ដើម្បីរៀបចំសកម្មភាពលក់ដូរ គេត្រូវមកដល់សាលានៅម៉ោង ៧:00 ។ តើមានសំណួរអ្វីទៀត ?

# ឧបសម្ព័ន្ធ D

## ការវាយតម្លៃសកម្មភាពផ្សារប្រឌិត

បន្ទាប់ពីរយៈពេល ២ សប្តាហ៍នៃផ្សារប្រឌិតត្រូវបញ្ចប់  គ្រូថ្នាក់ទី ៥ និង ថ្នាក់ទី ៦  សួរសំណួរដូចខាងក្រោមដល់សិស្ស ÷

**4)** តើប្អូនជាអ្នកលក់ ឬ អ្នកទិញ ?

**5)** ប្រសិនជាប្អូនជាអ្នកទិញ :

- តើប្អូនបានចំណាយប្រាក់ប៉ុន្មាន ?
- តើប្អូនចូលចិត្តសេវាកម្មអ្វីខ្លះ ? ហេតុអ្វី ?
- តើប្អូនមិនពេញចិត្តនឹងសេវាកម្មណាខ្លះ ? ព្រោះអ្វី ?

**6)** ប្រសិនជាប្អូនជាអ្នកលក់ :

- តើប្អូនបានចំណាយទុនប៉ុន្មានមុនចាប់ផ្តើមលក់ ?
- តើប្អូនបានប្រាក់ចំណេញប៉ុន្មាន ?
- ប្រសិនជាប្អូនធ្វើជាអ្នកលក់នៅផ្សារប្រឌិតនាពេលក្រោយ  តើប្អូនលក់សេវាកម្មដដែល ឬ សេវាកម្មផ្សេងទៀត ? ពីព្រោះអ្វី ?